# المختصر في صفة الحج

# សេចក្តីសង្ខេបអំពីរបៀបនៃការធ្វើ
# ហាជ្ជី

# សេចក្តីសង្ខេបអំពីរបៀបនៃការធ្វើហាជ្ជី

الحمد لله رب العالمين، والصلاة والسلام على نبينا محمد، وعلى آله وصحبه أجمعين.

បន្ទាប់មក៖

នេះគឺជាសារសង្ខេបអំពីរបៀបនៃការធ្វើហាជ្ជី ដែលយើងបានព្យាយាមរៀបរាប់អំពីប្រការចម្បងដែលអ្នកធ្វើហាជ្ជីចាំបាច់ត្រូវដឹង។

យើងសុំឱ្យអល់ឡោះជាម្ចាស់ប្រទាននូវភាពបរិសុទ្ធចំពោះកិច្ចការមួយនេះសម្រាប់ទ្រង់តែមួយគត់ និងក្លាយជាប្រយោជន៍ដល់ប្រជាជនម៉ូស្លីមទាំងអស់គ្នា។

គណៈកម្មាធិការនៃអង្គការបម្រើការមាតិកាអ៊ីស្លាមជាភាសានានា

## សេចក្តីផ្តើម

## ទីមួយ៖

## លក្ខខណ្ឌនៃការទទួលយកកិច្ចគោរពសក្ការៈ(អ៊ីហ្ពាទាត់)

កិច្ចគោរពសក្ការៈមិនត្រូវបានទទួលយកនោះឡើយ លើកលែងតែមានលក្ខខណ្ឌទាំងពីរនេះ៖

អៀហខ្លើស(ចិត្តស្មោះស)៖ ការមានចិត្តស្មោះសនៅក្នុងកិច្ចគោរពសក្ការៈចំពោះអល់ឡោះតែម្នាក់គត់។

ដូចដែលអល់ឡោះទ្រង់មានព្រះបន្ទូលថា៖

﴿وَمَآ أُمِرُوٓاْ إِلَّا لِيَعۡبُدُواْ ٱللَّهَ مُخۡلِصِينَ لَهُ ٱلدِّينَ حُنَفَآءَ...﴾"،

"ហើយពួកគេមិនត្រូវបានគេបញ្ជាឱ្យធ្វើអ្វីក្រៅពីឱ្យពួកគេគោរពសក្ការៈចំពោះអល់ឡោះ ដោយចិត្តស្មោះស និងត្រឹមត្រូវចំពោះទ្រង់ឡើយ[1]" (គួរអាន ៩៨ : ៥) (អាល់ពៃយីណះ ៖ ៥)

ហើយព្យាការីមូហាំម៉ាត់ ﷺ ក៏បានមានប្រសាសន៍ថាៈ

«إِنَّمَا الْأَعْمَالُ بِالنِّيَّاتِ، وَإِنَّمَا لِكُلِّ امْرِئٍ مَا نَوَى».

"ពិតប្រាកដណាស់ កិច្ចការ(អាម៉ាល់)ទាំងឡាយអាស្រ័យទៅតាមគោលបំណង(នៀត) ហើយបុគ្គលគ្រប់រូបនឹងទទួលបានផល(ការតបស្នង) តាមអ្វីដែលខ្លួនប៉ងប្រាថ្នា"។[2]

ត្រូវធ្វើតាមព្យាការីទាំងពាក្យសំដី និងទង្វើ។ ព្យាការីមូហាំម៉ាត់ ﷺ បានមានប្រសាសន៍ថាៈ

«مَنْ أَحْدَثَ فِي أَمْرِنَا هَذَا مَا لَيْسَ فِيهِ فَهُوَ رَدٌّ».

"បុគ្គលណាដែលបង្កើតអ្វីមួយថ្មីនៅក្នុងកិច្ចការសាសនារបស់យើង ដោយវាពុំមែនជាកិច្ចការដែលបានមកពីយើងទេនោះ គឺនឹងត្រូវគេបដិសេធចោល"[3] (រាយការណ៍ដោយ

---

1 នោះគឺៈ បំណងនៃកិច្ចគោរពសក្ការៈគឺសំដៅទៅកាន់ទ្រង់តែមួយគត់ ដាកចេញពីអ្វីដែលផ្សេងពីទ្រង់ (តាហ្វសៀរ អាសសាក់ទី : ទំព័រ ៩៣៨)

2 រាយការណ៍ដោយអ៊ីម៉ាំ ពូខរី លេខ ១ និង អ៊ីម៉ាំ មូស្លីម លេខ ១៩០៧

3 រាយការណ៍ដោយអ៊ីម៉ាំ ពូខរី លេខ ២៦៩៧ និង អ៊ីម៉ាំ មូស្លីម លេខ ១៧១៨

អ៊ីម៉ាំអាល់ពូខរី : ២៦៩៧ និង មូស្លីម : ១៧១៨) ហើយនៅក្នុងសេចក្តីរាយការណ៍ដោយមូស្លីម : (១៧១៨) វិញគឺ៖

«مَنْ عَمِلَ عَمَلًا لَيْسَ عَلَيْهِ أَمْرُنَا فَهُوَ رَدٌّ».

"បុគ្គលណាដែលធ្វើទង្វើ(អាម៉ាល់)អ្វីមួយ ដោយវាពុំមែនជាកិច្ចការដែលបានមកពីយើងទេ នោះ គឺនឹងត្រូវគេបដិសេធចោល"[4]

***

## ទីមួយ៖ ក្បួនច្បាប់នៃមីកត

មីកត គឺជាកន្លែងទាំងឡាយដែលព្យាការីមូហាំម៉ាត់បានកំណត់ដើម្បីចាប់ផ្តើមនៀត(ប៉ង)អៀហរ៉ម សម្រាប់អ្នកដែលមានបំណងចង់ធ្វើហាជ្ជី ឬអ៊ុំរ៉ោះ។

ជនណាដែលឆ្លងកាត់កន្លែងណាមួយនៃមីកតនោះដោយមានបំណងចង់ធ្វើហាជ្ជី ឬអ៊ុំរ៉ោះ គឺចាំបាច់ត្រូវនៀត(ប៉ង)អៀហរ៉មពីកន្លែងនោះ។ ដោយមិនត្រូវបានអនុញ្ញាតឱ្យឆ្លងកាត់វាដោយមិនបានអៀហរ៉មឡើយ។

អ្នកដែលនៅជិតម៉ាក្កះ នោះកន្លែងនៀត(ប៉ង)អៀហរ៉មរបស់គេគឺកន្លែងរបស់គេ។ ដោយគេត្រូវនៀត(ប៉ង)អៀហរ៉មសម្រាប់ធ្វើហាជ្ជី និងអ៊ុំរ៉ោះ ពីទីនោះ។

[4] រាយការណ៍ដោយអ៊ីម៉ាំ មូស្លីម លេខ ១៧១៨

ចំពោះប្រជាជនម៉ាក្កះ និងអ្នកដែលមានបំណងនៀត(ប៉ង)អៀហរ៉មពីទីនោះ៖ ពួកគេត្រូវនៀត(ប៉ង)អៀហរ៉មសម្រាប់ហាជ្ជីពីម៉ាក្កះ។ រីឯអ៊ុំរ៉ោះវិញ ពួកគេត្រូវចេញទៅក្រៅទឹកដីហារ៉មហើយនៀត(ប៉ង)អៀហរ៉មពីទីនោះដូចជានៅកន្លែងតាន់អ៊ីម និងកន្លែងផ្សេងទៀត។

ហើយសម្រាប់អ្នកដែលជិះយន្តហោះ៖ គាត់ត្រូវនៀត(ប៉ង)អៀហរ៉មនៅពេលគាត់ទៅដល់កន្លែងដែលបានកំណត់សម្រាប់នៀត(ប៉ង)អៀហរ៉មនោះ។ ដូច្នេះគាត់ត្រូវរៀបចំនិងស្លៀកពាក់អៀហរ៉មមុនពេលទៅដល់មីកត(កន្លែងដែលត្រូវនៀត(ប៉ង)អៀហរ៉ម) ហើយនៅពេលគាត់ទៅដល់នោះគឺគាត់ត្រូវនៀត(ប៉ង)អៀហរ៉មភ្លាមៗ ដោយមិនអនុញ្ញាតឱ្យគាត់ពន្យារពេលរហូតដល់គាត់ចុះចតនៅអាកាសយានដ្ឋានឡើយ ហើយគាត់អាចធ្វើការតាល់ពីយ៉ះមុនទៅដល់មីកត ព្រោះខ្លាចមិនទាន់ ដោយសារល្បឿនលឿននៃយន្តហោះ។

## ទីពីរ៖ ប្រភេទនៃការធ្វើហាជ្ជី និងក្បួនច្បាប់របស់វា

ចំពោះហាជ្ជី គឺមានបីប្រភេទ៖ ហាជ្ជីតាម៉ាត់តួក ហាជ្ជីអ៊ីហ្វរ៉ទ និងហាជ្ជីគីរ៉ន។

ហើយហាជ្ជីតាម៉ាត់តួក គឺល្អជាងគេសម្រាប់អ្នកដែលមានសត្វជំនូនសំឡេះ។

ដោយគេត្រូវអៀហរ៉មអ៊ុមរ៉ោះក្នុងបណ្ដាខែហាជ្ជី ហើយត្រូវធ្វើដំណើរទៅកាន់ម៉ាស្ជិតអាល់ហារ៉មដើម្បីធ្វើអ៊ុមរ៉ោះ(តវ៉ាហ្វ សាអ៊ី រួចកោរសក់ ឬកាត់វាដើម្បីបញ្ចប់អៀហរ៉ម) បន្ទាប់មក គេត្រូវអៀហរ៉មដើម្បីធ្វើហាជ្ជីម្ដងទៀតនៅក្នុងឆ្នាំដដែលនោះ។

ហាជ្ជីអ៊ិហ្វរ៉ទះ គឺគេអៀហរ៉មហាជ្ជីតែមួយប៉ុណ្ណោះ។ បន្ទាប់មក នៅពេលដែលគេទៅដល់ម៉ាក្កះ គេគប្បីតវ៉ាហ្វគូទូម(តវ៉ាហ្វពេលទៅដល់)។ បន្ទាប់មក ត្រូវសាអ៊ីសម្រាប់ហាជ្ជីរបស់គេ(គេអាចសាអ៊ីក្រោយពេលតវ៉ាហ្វគូទូមរួច ឬក៏ពន្យារពេលរហូតដល់តវ៉ហ្វអ៊ីហ្វាហ្ពោះរួចក៏បាន)។ ហើយគេមិនអាចកាត់ឬកោរសក់ និងតាហាល់លុល(បញ្ចប់អៀហរ៉ម)ឡើយ។ ផ្ទុយទៅវិញ គេត្រូវបន្តស្ថិតនៅក្នុងអៀហរ៉មរបស់ខ្លួន រហូតដល់ពេលគប់គោលអាក៏ហ្ពះនាថ្ងៃរ៉យ៉ាហាជ្ជី និងបានកោរសក់រួច។

ហាជ្ជីគីរ៉នះ គឺគេត្រូវអៀហរ៉មអ៊ុមរ៉ោះនិងហាជ្ជីជាមួយគ្នា។ ហើយគេត្រូវសូត្រនៅពេលអៀហរ៉មថា៖ (لبيك اللهمّ عمرة وحجا)។

ការធ្វើហាជ្ជីគីរ៉នគឺដូចគ្នាទៅនឹងការធ្វើហាជ្ជីអ៊ិហ្វរ៉ទដែរ តែខុសត្រង់អ្នកដែលធ្វើហាជ្ជីគីរ៉ននេះ តម្រូវសំឡេះសត្វជំនូន រីឯហាជ្ជីអ៊ិហ្វរ៉ទមិនតម្រូវសំឡេះសត្វជំនូននោះទេ។

## ទីបី៖ របៀបធ្វើហាជ្ជី និងក្បួនច្បាប់របស់វា

ចំពោះអ្នកដែលចង់(ប៉ង)អៀហរ៉មធ្វើហាជ្ជី គឺគេត្រូវអនុវត្តដូចខាងក្រោម៖

ងូតទឹក ដែលវាគឺជាស៊ុណ្ណះដែលត្រូវបានជំរុញណែនាំសម្រាប់បុរស និងស្ត្រី សូម្បីតែស្ត្រីដែលមករដូវ និងស្ត្រីក្រោយសម្រាលកូន។

ប្រើទឹកអប់ដែលល្អបំផុតដែលគេមាននៅលើក្បាល និងពុកចង្ការរបស់គេ ហើយគ្មានបញ្ហាអ្វីឡើយប្រសិនបើមានសល់ស្លាកស្នាមបន្ទាប់ពីអៀហរ៉ម។ ចំពោះស្ត្រីវិញ គឺហាមប្រើទឹកអប់ ដើម្បីកុំឱ្យបុរសដទៃស្រង់ក្លិនរបស់នាង។

ស្លៀកសម្លៀកបំពាក់អៀហរ៉ម ដែលជាក្រណាត់ពីរដុំ(សម្រាប់រុំផ្នែកខាងលើ និងខាងក្រោម) ហើយតាមស៊ុណ្ណះគួរប្រើក្រណាត់ពណ៌សដែលស្អាត ឬថ្មី។ ចំណែកស្ត្រីអាចស្លៀកអ្វីក៏បានដែលនាងពេញចិត្ត ដោយមិនបង្ហាញភាពឆើតឆាយ ហើយជៀសវាងពាក់និកប(ក្រណាត់បិទមុខ) និងពាក់ស្រោមដៃ ដោយគេអាចគ្របមុខ និងដៃរបស់នាងជាមួយអ្វីផ្សេងទៀតបាន។

ច្បាប់បានចែងគួគម្បីសឡាតមុននឹងនៀត(ប៉ង)អៀហរ៉ម ជាសឡាតហ្វើរទូ ឬសឡាតស៊ូណិត តែមិនមែនវ៉ាជិប(ចាំបាច់)នោះទេ។

គេត្រូវសូត្រនៅពេលអៀហរ៉មថា៖ (لبيك اللهمّ عمرة متمتعاً بها إلى الحج) បើគេធ្វើហាជ្ជីតាម៉ាត់តួក ។ ឬត្រូវសូត្រថា៖ (لَبيك حجا) បើគេធ្វើហាជ្ជីអ៊ីហ្វរ៉ទ។ ឬត្រូវសូត្រថា៖ (لَبيك اللهمّ عمرة وحجا) បើគេធ្វើហាជ្ជីគីរ៉ន។

ប្រសិនបើអ្នកនៀត(ប៉ង)អៀហរ៉ម ខ្លាចមានឧបសគ្គដែលនឹងរារាំងគេពីការបញ្ចប់ការធ្វើអ៊ុំរ៉ោះនោះ គេគួរតែដាក់លក្ខខណ្ឌពេលនៀត(ប៉ង)អៀហរ៉មនោះ ដោយសូត្រថា៖ (لبيك اللهم عمرة، وإن حبسني حابس فمحلي حيث حبستني) " ឡាប់ពៃកល់ឡហ៊ុមម៉ាអ៊ុំរ៉ោះ វ៉ាអិនហាប៉ាសានីហាពីសុន វ៉ាម៉ាហាល់លី ហៃស្ទ៊ហាប៉ាសតានី " ។ ប្រសិនបើគេបានដាក់លក្ខខណ្ឌហើយមានអ្វីមួយដែលរារាំងគេពីការបញ្ចប់ការធ្វើអ៊ុំរ៉ោះ នោះគេអាចបញ្ចប់អៀហរ៉មនៅពេលនោះ ឬកន្លែងនោះបាន។

បន្ទាប់មកគេគប្បីសូត្រតាល់ពីយ៉ះឱ្យបានច្រើន ដោយពោលថា៖ : (لبيك اللهم لبيك، لبيك لا شريك لك لبيك، إن الحمد والنعمة لك والملك لا شريك لك)។ ចំពោះបុរសត្រូវសូត្រវាដោយបន្លឺសំឡេង និងស្ត្រីក៏ដូចគ្នាដែរនៅពេលដែលគ្មានវត្តមានបុរសដែលមិនមែនជាមួសរ៉ម។ហើយគប្បីលើគេសូត្រតាល់ពីយ៉ះឱ្យបានច្រើនជាពិសេសនៅពេលដែលផ្លាស់ប្តូរកន្លែង និងពេលវេលា ដូចជានៅពេលដែលគេឡើងទៅកាន់ទីខ្ពស់

ឬចុះទៅទីទាប ឬពេលដែលយប់ ឬថ្ងៃជិតចូលមកដល់។[5]

ការសូត្រតាល់ពីយ៉ះសម្រាប់អ្នកធ្វើអ៊ុំរ៉ោះ គឺគប្បីធ្វើវាចាប់តាំងពីផ្តើមនៀត(ប៉ង)អៀហរ៉ាម រហូតដល់ចាប់ផ្តើមតវ៉ាហ្វ(ដើរប្រទក្សិណជុំវិញកាក់ហ្ពះ)។ រីឯសម្រាប់អ្នកធ្វើហាជ្ជីវិញ គឺចាប់តាំងពីផ្តើមនៀត(ប៉ង)អៀហរ៉ាមរហូតដល់ចាប់ផ្តើមគប់គោលអាក័ហ្ពះនៅថ្ងៃរ៉យ៉ា។

អ្នកដែលកំពុងស្ថិតនៅក្នុងអៀហរ៉ាម ត្រូវតែប្រុងប្រយ័ត្នកុំឱ្យធ្លាក់ចូលទៅក្នុងប្រការដែលគេបានហាមឃាត់ណាមួយក្នុងអំឡុងពេលនោះ រហូតដល់គេត្រូវបានបញ្ចប់រួចរាល់ពីអៀហរ៉ាមជាមុនសិន។

## ទីបួន៖ បម្រាមទាំងឡាយនៃអៀហរ៉ាម

បម្រាមទាំងឡាយនៃអៀហរ៉ាមមានដូចជា៖

5 អត្ថន័យនៃពាក្យតាល់ពីយ៉ះគឺ៖ «لبيك» គឺឆ្លើយតបនឹងបទបញ្ជារបស់ទ្រង់ និងគោរពប្រណិបតន៍របស់គេចំពោះទ្រង់ ជាបន្តបន្ទាប់។ « إن الحمد والنعمة لك والملك» គឺជាការសរសើរដ៏ពេញលេញទៅចំពោះទ្រង់ ដោយក្តីស្រឡាញ់ និងការគោរពតម្កើង ដែលទ្រង់ប្រទានដល់អ្នកបម្រើរបស់ទ្រង់នូវលាភសក្ការៈជាច្រើនដែលគេចង់បាន និងបញ្ចៀសពីអ្វីដែលគេមិនពេញចិត្ត។ ហើយទ្រង់គឺជាស្តេចតែមួយអង្គគត់ដែលមហាខ្លាំងក្លា។ «لا شريك لك» គឺគ្មាននរណាម្នាក់ដែលរួចចំណែកជាមួយទ្រង់នូវអ្វីដែលជាក់លាក់សម្រាប់ទ្រង់នោះឡើយចំពោះលក្ខណៈដ៏ល្អឥតខ្ចោះរបស់ទ្រង់ ដោយទ្រង់តែម្នាក់គត់ដែលជាស្តេច ជាអ្នកបង្កើត គ្រប់គ្រង និងត្រូវគេគោរពសក្ការៈ។ សេចក្តីសង្ខេប (22/ 96) مجموع فتاوى ورسائل العثيمين ។

កោរ ឬកាត់ ឬដកសក់និងរោមនៃផ្នែកណាមួយនៃរាងកាយ។

កាត់ក្រចកដៃ ឬក្រចកជើង។

គ្របក្បាលនឹងអ្វីមួយដែលជាប់នឹងក្បាល ដូចជា៖ សាល់ មួក ក្រណាត់ កន្សែងឬអ្វីផ្សេងពីនេះ។ រីឯការគ្របក្បាលពីខាងលើ(មិនជាប់ផ្ទាល់នឹងក្បាល) ដូចជាដំបូលយានជំនិះ ឬឆ័ត្រជាដើម គឺគ្មានបញ្ហាឡើយ។ នេះជាបម្រាមដែលគេហាមឃាត់ចំពោះតែបុរសប៉ុណ្ណោះ។

ស្លៀកសម្លៀកបំពាក់មានថ្នេរដែលគេតែងពាក់វាជាធម្មតា ដូចជា៖ អាវ ខោ អាវក្រៅ ស្រោមជើង និងស្រោមដៃជាដើម។ នេះជាបម្រាមដែលគេហាមឃាត់ចំពោះតែបុរសប៉ុណ្ណោះ។ ចំណែកស្ត្រីវិញគឺត្រូវបានហាមឃាត់ដូចជា៖

ពាក់ស្បៃគ្របមុខ និងបិទមុខ៖ ស្ត្រីត្រូវបើកមុខរបស់ខ្លួន(ក្នុងពេលស្ថិតក្នុងតំណមអៀហរ៉ម) លើកលែងតែពេលដែលមានបុរសដទៃ(ដែលអាចរៀបការនឹងគ្នាបាន)ដើរកាត់ប៉ុណ្ណោះ។ ពេលនោះនាងអាចគ្របមុខរបស់នាងបាន ហើយបើទោះជាក្រណាត់គ្របមុខនោះប៉ះស្បែកមុខរបស់នាងក៏ដោយ ក៏គ្មានបញ្ហាអ្វីដែរ។

ការពាក់ស្រោមដៃ ហើយនៅតែពេលដែលមានបុរសដទៃ(ដែលអាចរៀប

ការនឹងគ្នាបាន)
ដើរកាត់ឬនៅជិតគឺនាងត្រូវដាក់ដៃចូលទៅខាងក្នុងអាវរបស់នាង។
ប្រើប្រាស់គ្រឿងក្រអូប និងទឹកអប់ មិនថាលើសម្លៀកបំពាក់ ឬលើខ្លួនប្រាណឡើយ។
សម្លាប់សត្វ ឬប្រមាញ់សត្វទោះបីជាមិនសម្លាប់វាក៏ដោយ។
ធ្វើការភ្ជាប់ពាក្យ មិនថាសម្រាប់ខ្លួនឯងឬអ្នកដទៃនោះទេ។
រៀបអាពាហ៍ពិពាហ៍(អាកត់នីកាស)។
ការប៉ះពាល់គ្នាប្ដីប្រពន្ធ ដូចជាឱបថើប ស្ទាបអង្អែលដោយមានចំណង់តណ្ហា។
រួមមេត្រីរវាងប្ដីប្រពន្ធ។
***

## ទីប្រាំ៖ របៀបតវ៉ាហ្វ(ការដើរប្រទក្សិណជុំវិញកាក់ហ្ពះ)

នៅពេលដែលគេចូលដល់ម៉ាស្ជិតអាល់ហារ៉ម គេគប្បីឈានជើងស្ដាំចូលមុន និងត្រូវសូត្រទូអាពេលចូលម៉ាស្ជិត ហើយទូអាដែលត្រឹមត្រូវនោះសូត្រថា៖ " اللهم افتح لي أبواب رحمتك" ។ វាជាទូអាដែលគប្បីសូត្រវានៅពេលចូលម៉ាស្ជិតទាំងឡាយ មិនសម្រាប់តែម៉ាស្ជិតអាល់ហារ៉មឡើយ។
ពេលដែលគេទៅដល់កាក់ហ្ពះ គឺត្រូវបញ្ឈប់ការសូត្រតាល់ពីយ៉ះមុននឹងគេចាប់ផ្ដើម

តវ៉ាហ្វ។ ហើយចំពោះបុរស គេគប្បីតវ៉ាហ្វដោយបើកស្មាស្តាំ ដោយត្រូវដាក់ក្រណាត់អៀហរ៉មពីក្រោមក្លៀកខាងស្តាំ និងដាយអៀហរ៉មពីលើស្មាឆ្វេង។ នៅពេលដែលគេបញ្ចប់តវ៉ាហ្វ គឺត្រូវគ្របស្មារបស់គេវិញ ពីព្រោះថាការបើកស្មាសម្រាប់តែពេលតវ៉ាហ្វប៉ុណ្ណោះ។

ដើម្បីចាប់ផ្តើមតវ៉ាហ្វ គេគប្បីដើរឆ្ពោះទៅកាន់ហាជើរ៉ុលអាសវ៉ាត់(ថ្មខ្មៅ) ហើយឱ្យសាឡាមដោយយកដៃស្តាំប៉ះលើវា រួចថើបវា។ តែប្រសិនបើមិនមានភាពងាយស្រួលក្នុងការធ្វើដូច្នេះទេ គឺត្រូវបែរខ្លួនទៅកាន់វា រួចលើកដៃស្តាំតម្រង់ទៅកាន់វាគឺគ្រប់គ្រាន់ហើយ។ ជាការល្អប្រសើរ គឺមិនត្រូវប្រជ្រៀតគ្នា ដែលបង្កជាផលប៉ះពាល់ និងមានការលំបាកដល់អ្នកដទៃនោះឡើយ។

ហើយនៅពេលឱ្យសាឡាមដោយយកដៃស្តាំប៉ះលើហាជើរ៉ុលអាស់វ៉ាត់ ឬលើកដៃតម្រង់ទៅវានោះគឺគប្បីសូត្រថា៖ (الله أكبر)(អល់ឡហ៊ូអ៊ឹកពើរ) ។

បន្ទាប់មកត្រូវចាប់ផ្តើមពីស្តាំ ដោយដាក់កាក់ហ្ពះនៅខាងឆ្វេងដៃ នៅពេលទៅដល់ជ្រុងយ៉ាម៉ានី គេគប្បីស្ទាបវា តែមិនតម្រូវឲ្យថើបឡើយ។ តែបើមិនមានភាពងាយស្រួលក្នុងការធ្វើដូចនោះទេ

ចូរកុំប្រជ្រៀតគ្នាដើម្បីធ្វើវា ហើយមិនតម្រូវឲ្យលើកដៃតម្រង់ទៅវាពីចម្ងាយនោះទេ។

ហើយនៅចន្លោះរវាងជ្រុងយ៉ាម៉ានី និងហាជើរ៉ុលអាសវ៉ាត់ គេគប្បីសូត្រថា៖ (رَبَّنَا آتِنَا فِي الدُّنْيَا حَسَنَةً وَفِي الْآخِرَةِ حَسَنَةً وَقِنَا عَذَابَ النَّار) ។

រាល់ពេលដែលគេឆ្លងកាត់ហាជើរ៉ុលអាសវ៉ាត់ គឺត្រូវលើកដៃតម្រង់តៅកាន់វា ហើយសូត្រ( الله أكبر)(អល់ឡហ៊ូអឹកពើរ) ។

ហើយនៅពេលតវ៉ាហ្វគេអាចសុំទូអា ហ្ស៊ីកៀរ និងសូត្រអាល់គួរអានតាមដែលគេពេញចិត្ត។

តាមស៊ុណ្ណះចំពោះបុរសគប្បីរត់តិចៗនៅបីជុំដំបូង រីឯបួនជុំចុងក្រោយមិនត្រូវរត់តិចៗនោះទេ គឺដើរធម្មតា។

នៅពេលដែលគេតវ៉ាហ្វបានគ្រប់ប្រាំពីរជុំហើយ គេត្រូវដើរឆ្ពោះទៅកាន់ផ្នែកខាងក្រោយនៃម៉ាកមអ៊ីព្រាហ៊ីម ហើយសូត្រថា៖ (وَاتَّخِذُوا مِنْ مَقَامِ إِبْرَاهِيمَ مُصَلّى) ហើយសឡាតពីររ៉ក្កាត់នៅទីនោះប្រសិនបើមានភាពងាយស្រួល ឬកន្លែងណាក៏បានក្នុងម៉ាស្ជិតអាល់ហារ៉ម ប្រសិនបើមានការលំបាក ឬចង្អៀត។ក្នុងរ៉ក្កាត់ទីមួយ បន្ទាប់ពីសូត្រអាល់ហ្វាទីហះ គេត្រូវសូត្រស៊ូរ៉ោះ៖ អាល់កាហ្វីរូន (قُلْ يَا أَيُّهَا الْكَافِرُون) ហើយក្នុងរ៉ក្កាត់ទីពីរ បន្ទាប់ពីសូត្រអាល់ហ្វាទីហះ គេត្រូវសូត្រស៊ូរ៉ោះ៖ អាល់អៀខ្លើស (قُلْ هُوَ اللَّهُ أَحَد) ។

﴿...وَٱتَّخِذُواْ مِن مَّقَامِ إِبۡرَٰهِـۧمَ مُصَلّٗى...﴾

(...ហើយចូរពួកអ្នកយកម៉ាកមអ៊ីព្រហ៊ីមជាកន្លែងសឡាត...) [អាល់ប៉ាក៏រ៉ោះ ៖ ១២៥] ហើយសឡាតពីររ៉ក្កាត់នៅទីនោះប្រសិនបើមានភាពងាយស្រួល ឬកន្លែងណាក៏បានក្នុងម៉ាស្ជិតអាល់ហារ៉មប្រសិនបើមានការលំបាក ឬចង្អៀត។ ក្នុងរ៉ក្កាត់ទីមួយ បន្ទាប់ពីសូត្រអាល់ហ្វាទីហះ គេត្រូវសូត្រស៊ូរ៉ោះ៖

﴿قُلۡ يَٰٓأَيُّهَا ٱلۡكَٰفِرُونَ﴾

(قُلۡ يَٰٓأَيُّهَا ٱلۡكَٰفِرُون) [អាល់កាហ្វីរ៉ូន ៖ ១ ] ក្នុងរ៉ក្កាត់ទីពីរ បន្ទាប់ពីសូត្រអាល់ហ្វាទីហះ គេត្រូវសូត្រស៊ូរ៉ោះ៖

﴿قُلۡ هُوَ ٱللَّهُ أَحَدٌ﴾.

(قُلۡ هُوَ ٱللَّهُ أَحَد) [អាល់អ៊ិខ្លើស ៖ ១ ]

## ទីប្រាំមួយៈ របៀបសាអ៊ី

ក្រោយតវ៉ាហ្វ និងសឡាតរួចរាល់ គេត្រូវចាកចេញទៅកាន់កន្លែងសាអ៊ី។ នៅពេលដែលគេទៅជិតដល់ភ្នំសហ្វា គេត្រូវសូត្របន្ទូលរបស់អល់ឡោះ៖ (إِنَّ الصَّفَا وَالْمَرْوَةَ مِنْ شَعَائِرِ اللَّه) រួចមក ពោលថា៖ "أبدأ بما بدأ الله به" ។

﴿إِنَّ ٱلصَّفَا وَٱلۡمَرۡوَةَ مِن شَعَآئِرِ ٱللَّهِ...﴾

(إِنَّ ٱلصَّفَا وَٱلۡمَرۡوَةَ مِن شَعَآئِرِ ٱللَّه...) បន្ទាប់មកសូត្រថា៖

«أَبْدَأُ بِمَا بَدَأَ اللهُ بِهِ».

< [6]<أَبْدَأُ بِمَا بَدَأَ اللهُ بِهِ

---

[6] រាយការណ៍ដោយ អ៊ីមុាំ មូស្លីម លេខ ១២១៨

បន្ទាប់មក ត្រូវឡើងលើភ្នំសហ្វា រួចតម្រង់ទៅកាន់កាក់ហ្ពះ លើកដៃទាំងពីរសូត្រ (الله أكبر) បីដងរួចសូត្រថា៖ (لا إله إلا الله وحده لا شريك له، له الملك وله الحمد، وهو على كل شيء قدير، لا إله إلا الله وحده، أنجز وعده، ونصر عبده، وهزم الأحزاب وحده) សូត្រវាចំនួនបីដង។ និងបួងសួងសុំទូអានូវអ្វីដែលគេប្រាថ្នា។

**«لَا إِلَهَ إِلَّا اللهُ وَحْدَهُ لَا شَرِيكَ لَهُ، لَهُ الْمُلْكُ وَلَهُ الْحَمْدُ، وَهُوَ عَلَى كُلِّ شَيْءٍ قَدِيرٌ، لَا إِلَهَ إِلَّا اللهُ وَحْدَهُ، أَنْجَزَ وَعْدَهُ، وَنَصَرَ عَبْدَهُ، وَهَزَمَ الْأَحْزَابَ وَحْدَهُ»، ثُمَّ دَعَا بَيْنَ ذَلِكَ. قَالَ مِثْلَ هَذَا ثَلَاثَ مَرَّاتٍ.**

لَا إِلَهَ إِلَّا اللهُ وَحْدَهُ لَا شَرِيكَ لَهُ، لَهُ الْمُلْكُ وَلَهُ الْحَمْدُ، وَهُوَ عَلَى كُلِّ شَيْءٍ » قَدِيرٌ، لَا إِلَهَ إِلَّا اللهُ وَحْدَهُ، أَنْجَزَ وَعْدَهُ، وَنَصَرَ عَبْدَهُ، وَهَزَمَ الْأَحْزَابَ وَحْدَهُ»، ثُمَّ دَعَا بَيْنَ ذَلِكَ. قَالَ مِثْلَ هَذَا ثَلَاثَ مَرَّاتٍ.[7]

បន្ទាប់មក ត្រូវចុះពីភ្នំសហ្វា រួចដើរតម្រង់ទៅកាន់ភ្នំម៉ារវ៉ះ។ លុះពេលគេទៅដល់បង្គោលបៃតងទាំងពីរ ចំពោះបុរសគប្បីត្រូវរត់តិចៗនៅចន្លោះបង្គោលទាំងពីរនោះ ចំណែកឯស្ត្រីវិញ គឺត្រូវដើរធម្មតា។

នៅពេលទៅដល់ភ្នំម៉ារវ៉ះ គឺត្រូវតម្រង់ទៅកាន់កាក់ហ្ពះ ហើយលើកដៃទាំងពីរ រួចសូត្រដូចអ្វីដែលគេបានសូត្រនៅភ្នំសហ្វាដែរ។ (កថាខណ្ឌលេខ ២)

បន្ទាប់មក ត្រូវចុះពីភ្នំម៉ារវ៉ះ រួចដើរសំដៅទៅកាន់ភ្នំសហ្វាវិញ។ លុះពេលគេទៅដល់បង្គោលបៃតងទាំងពីរ

---

[7] រាយការណ៍ដោយ អ៊ីម៉ាំ មូស្លីម លេខ ១២១៨

ចំពោះបុរសគប្បីត្រូវរត់តិចៗនៅចន្លោះបង្គោលទាំងពីរនោះ។

គេត្រូវធ្វើបែបនេះ រហូតដល់គ្រប់ប្រាំពីរជុំ។ ពេលចេញពីភ្នំសហ្វាទៅដល់ភ្នំម៉ារវ៉ះ រាប់ថាមួយជុំ ហើយពេលត្រឡប់មកវិញ រាប់ថាមួយជុំទៀត។

ក្នុងពេលសាអ៊ី ស៊ូណិតបង្កើននូវការហ្សិកៀរ សូត្រអាល់គួរអាន និងសុំទូអាតាមដែលគេពេញចិត្ត។

ទីប្រាំពីរៈ របៀបនៃការកោរ ឬកាត់សក់

នៅពេលដែលអ្នកធ្វើអ៊ុំរ៉ោះបានបញ្ចប់ការតវ៉ាហ្វ និងសាអ៊ីរួចរាល់ គេត្រូវកាត់សក់ ឬកោរសក់។ ដោយស៊ុណ្ណះ គប្បីត្រូវកាត់ ឬកោរសព្វពេញក្បាលរបស់គេ សម្រាប់បុរស។

ការកោរ គឺប្រសើរជាងកាត់។ លើកលែងតែគេធ្វើហាជ្ជី ហើយថ្ងៃធ្វើហាជ្ជីខិតជិតមកដល់ ដោយខ្លាចសក់ដុះមិនទាន់ នោះកាត់សក់ខ្លីគឺជាការល្អ។

ចំណែកឯស្ត្រីវិញគឺត្រូវកាត់សក់របស់នាងប្រវែងមួយថ្នាំងដៃ។

រីឯអ្នកអៀហរ៉មធ្វើហាជ្ជីអ៊ីហ្វរ៉ទ ឬហាជ្ជីគីរ៉ន គឺមិនត្រូវកាត់ ឬកោរសក់របស់គេឡើយ រហូតដល់ថ្ងៃរ៉យ៉ាបន្ទាប់ពីគប់គោលអាក៏ហ្ពះរួច។

ដោយធ្វើដូចនេះរួច មានន័យថា អ្នកធ្វើអ៊ុំរ៉ោះ ឬអ្នកធ្វើហាជ្ជីតាម៉ាត់តួក បានបញ្ចប់អ៊ុំរ៉ោះរបស់គេចប់សព្វគ្រប់ហើយ។

# របៀបនៃការធ្វើហាជ្ជី

## ទីមួយ៖ អៀហរ៉មហាជ្ជី

ស៊ុណ្ណះសម្រាប់អ្នកដែលមានបំណងនៀតអៀហរ៉មហាជ្ជី គឺគេត្រូវនៀតនៅពេលទូហាមុនថ្ងៃត្រង់ក្នុងថ្ងៃតើរវិយ៉ះ ដែលជាថ្ងៃទីប្រាំបីនៃខែហ្ស៊ុលហ៊ិជ្ជះ ពីទីកន្លែងដែលគេចង់ធ្វើហាជ្ជីនោះ សម្រាប់អ្នកដែលនៅម៉ាក្កះ ឬអ្នកដែលនៅផ្សេងពីតំបន់មីកត។ ចំណែកអ្នកដែលត្រូវឆ្លងកាត់កន្លែងមីគតណាមួយ ចាំបាច់ត្រូវនៀតអៀហរ៉មពីកន្លែងនោះ។

ហើយគេត្រូវអនុវត្តនៅពេលអៀហរ៉មហាជ្ជីដូចគ្នាទៅនឹងពេលអៀហរ៉មអ៊ុំរ៉ោះដែរ ដូចជា៖ ងូតទឹក ប្រើគ្រឿងក្រអូប និងស្លៀកសម្លៀកបំពាក់អៀហរ៉មសឡាត នៀតអៀហរ៉មហាជ្ជី និងពោលតាល់ពីយ៉ះ លើកលែងតែធ្វើហាជ្ជីត្រូវពោលថា៖ ( لبيك حجًا ) ហើយធ្វើអ៊ុំរ៉ោះវិញ ត្រូវពោលថា៖ (لبيكَ عمرة)។

ប្រសិនបើអ្នកនៀត(ប៉ង)អៀហរ៉មខ្លាចមានឧបសគ្គដែលនឹងរារាំងគេពីការបញ្ចប់ការធ្វើអ៊ុំរ៉ោះនោះ គេគួរតែដាក់លក្ខខណ្ឌពេលនៀត(ប៉ង)អៀហរ៉មនោះដោយសូត្រថា៖ ( لبيك اللهم عمرة، وإن حبسني حابس فمحلي حيث حبستني) " ឡាប់ពៃកល់ឡហ៊ុមម៉ាអ៊ុំរ៉ោះ វ៉ាអិនហាប៉ាសានីហាពីសុន វ៉ាម៉ាហាល់លី ហៃស៊ូហាប៉ាសតានី " ។

ប្រសិនបើគេបានដាក់លក្ខខណ្ឌហើយមានអ្វីមួយដែលរារាំងគេពីការបញ្ចប់ការធ្វើអ៊ុំរ៉ោះ នោះគេអាចបញ្ចប់អៀហរ៉មនៅពេលនោះ ឬកន្លែងនោះបាន។

បន្ទាប់មកគេគប្បីសូត្រតាល់ពីយ៉ះឱ្យបានច្រើន ដោយពោលថា៖ : ( لبيك اللهم لبيك، لبيك لا شريك لك لبيك، إن الحمد والنعمة لك والملك لا شريك لك)។ ចំពោះបុរសត្រូវសូត្រវាដោយបន្លឺសំឡេង និងស្ត្រីក៏ដូចគ្នាដែរនៅពេលដែលគ្មានវត្តមានបុរសដែលមិនមែនជាមួសរ៉ម។ហើយគប្បីលើគេសូត្រតាល់ពីយ៉ះឱ្យបានច្រើនជាពិសេសនៅពេលដែលផ្លាស់ប្តូរកន្លែង និងពេលវេលា ដូចជានៅពេលដែលគេឡើងទៅកាន់ទីខ្ពស់ ឬចុះទៅទីទាប ឬពេលដែលយប់ ឬថ្ងៃជិតចូលមកដល់។

ការសូត្រតាល់ពីយ៉ះ គឺចាប់តាំងពីនៀត(ប៉ង)អៀហរ៉មរហូតដល់ចាប់ផ្តើមគប់គោលអាក៏ហ្ពះនៅថ្ងៃរ៉យ៉ា។

អ្នកដែលកំពុងស្ថិតនៅក្នុងអៀហរ៉ម ត្រូវតែប្រុងប្រយ័ត្នកុំឱ្យធ្លាក់ចូលទៅក្នុងប្រការដែលគេបានហាមឃាត់ណាមួយក្នុងអំឡុងពេលនោះ រហូតដល់គេត្រូវបានបញ្ចប់រួចរាល់ពីអៀហរ៉មជាមុនសិន។

***

## ទីពីរ៖ ការស្នាក់នៅមីណា

ក្រោយមក គប្បីរូបគេត្រូវចាកចេញទៅកាន់មីណាមុនថ្ងៃត្រង់ក្នុងថ្ងៃទី៨ ហើយត្រូវស្នាក់នៅនិងសឡាតហ្ស៊ូហោរ អាសើរ ម៉ាហ្គ្រិប អ៊ីស្ហា និងស៊ូពុសនៅទីនោះដោយត្រូវបង្រួមសឡាត(កសើរ) តែមិនត្រូវផ្គុំសឡាត(ជម៉ក់)នោះទេ។ ព្រោះព្យាការីមូហាំម៉ាត់ ﷺ លោកបានបង្រួមសឡាត(កសើរ) តែមិនផ្គុំសឡាត(ជម៉ក់)នោះទេ។

## ទីបី៖ ការស្នាក់នៅអារ៉ហ្វះនិងមុហ្សទើលីហ្វះ

នៅពេលថ្ងៃរះនាថ្ងៃអារ៉ហ្វះដែលជាថ្ងៃទីប្រាំបួននៃខែហ្ស៊ុលហិជ្ជះ អ្នកធ្វើហាជ្ជីត្រូវធ្វើដំណើរចាកចេញពីមីណាឆ្ពោះទៅកាន់អារ៉ហ្វះ ដោយស៊ូណិតឱ្យស្នាក់នៅឯ ណាមីរ៉ោះរហូតដល់ថ្ងៃជ្រេ ប្រសិនបើអាចធ្វើបាន តែបើមិនអាចធ្វើដូច្នេះទេក៏គ្មានបញ្ហានោះដែរ។

ហើយនៅពេលថ្ងៃជ្រេ គេត្រូវសឡាតហ្ស៊ូហ៊ូរ និងអាសើរ ដោយត្រូវបង្រួម និងផ្គុំសឡាត(កសើរ និងជម៉ក់) ដោយជម៉ក់តឹកទីម(យកសឡាតអាសើរមកសឡាតក្នុងពេលហ្ស៊ូហោរ) ដូចដែលព្យាការីធ្លាប់បានធ្វើ។

ក្រោយសឡាតរួច គេត្រូវធ្វើការហ្ស៊ីកៀរ និងសុំទូអាប្រកបដោយការទទួចអង្វរករចំពោះអល់ឡោះជាម្ចាស់។

គេត្រូវសុំទូអានូវអ្វីដែលគេចង់បានដោយលើកដៃទាំងពីរ តម្រង់ទៅកាន់គិបឡាត់។

ហើយទូអាដែលព្យាការីសូត្រច្រើនជាងគេនៅកន្លែងនោះគឺ៖ " لا إله إلا الله وحده لا شريك له، له الملك وله الحمد وهو على كل شيء قدير" ។

ប្រសិនបើគេអស់កម្លាំង ហើយចង់សម្រាក ឬចង់និយាយជាមួយមិត្តរបស់គេ នោះគេគួរសន្ទនាអំពីអ្វីដែលមានប្រយោជន៍ ឬអានសៀវភៅណាដែលមានប្រយោជន៍តាមដែលគេអាចធ្វើបាន ជាពិសេសសៀវភៅដែលទាក់ទងនឹងភាពសប្បុរស និងការប្រទានដ៏បរិបូររបស់អល់ឡោះ ដើម្បីពង្រឹងក្តីសង្ឃឹមនៅថ្ងៃនោះ ទើបជាការល្អ។ បន្ទាប់មកគេគួរត្រលប់ទៅបន្តសុំទូអាដោយការទទូចអង្វរករចំពោះអល់ឡោះជាម្ចាស់។ ហើយត្រូវចាប់យកឱកាសនៃការសុំទូអានៅមុនពេលថ្ងៃជិតលិច ព្រោះការទូអាដ៏ល្អបំផុតគឺការទូអានៅថ្ងៃអារ៉ហ្វះ។

ហើយនៅពេលថ្ងៃលិច អ្នកធ្វើហាជ្ជីត្រូវធ្វើដំណើរទៅកាន់មុហ្សទើលីហ្វះ។

ហើយនៅពេលអ្នកធ្វើហាជ្ជីទៅដល់មុហ្សទើលីហ្វះ គេត្រូវសឡាតម៉ាហ្គ្រិប និងអ៊ីស្ហា ដោយបង្រួម និងផ្គុំសឡាត(កសើរ និងជម៉ក់)។

ប្រសិនបើគេខ្លាចថានឹងមិនអាចទៅដល់មុហ្សទើលីហ្វះទេ រហូតទាល់តែពាក់កណ្តាលអធ្រាត្រ

នោះគេត្រូវសឡាតមុនពេលទៅដល់មុហ្សទើលីហ្វះ។ ព្រោះមិនអនុញ្ញាតឱ្យពន្យារពេលសឡាតរហូតដល់ហួសពាក់កណ្តាលអធ្រាត្រឡើយ។

ហើយត្រូវស្នាក់នៅមុហ្សទើលីហ្វះនេះ។ នៅពេលដល់ពេលហ្វាជើរះគេត្រូវសឡាតស៊ូពុស ដោយមានការអាហ្សាន និងអ៊ីក៏ម៉ាត់។

បន្ទាប់មក គេត្រូវធ្វើដំណើរទៅម៉ាសអារិលហារ៉ម ប្រសិនបើងាយស្រួលក្នុងការធ្វើដូច្នេះ ឬនៅកន្លែងរបស់គេ បើសិនមិនអាចទៅទីនោះបាន។ ធ្វើការស៊ីកៀរចំពោះអល់ឡោះ និងបួងសួងសុំទូអាចំពោះទ្រង់ ដោយតម្រង់ទៅកាន់គិបឡាត់ និងលើកដៃទាំងពីររហូតដល់ភ្លឺច្បាស់។ដូចដែរណាពីបានមានប្រសាសន៍ថា៖ (ខ្ញុំបានស្នាក់នៅទីនេះ ហើយទីកន្លែងនេះទាំងមូលជាកន្លែងស្នាក់នៅ) ហើយលោកបានស៊ីកៀរ និងបួងសួងសុំទូអា ដោយតម្រង់ទៅកាន់គិបឡាត់ និងលើកដៃទាំងពីរ។

«وَقَفْتُ هَاهُنَا وَجَمْعٌ كُلُّهَا مَوْقِفٌ»،

«ខ្ញុំបានស្នាក់នៅទីនេះ ហើយកន្លែងទាំងអស់នៅទីនេះ គឺជាកន្លែងសំណាក់»

ហើយនៅពេលដែលស៊ីកៀរ និងទូអាបួងសួង គឺត្រូវបែរទៅទិសគិបឡាត់ ហើយលើកដៃទាំងពីររបស់គេ។

## ទីបួន៖ ទង្វើនៅថ្ងៃរ៉យ៉ាហាជ្ជី

នៅពេលមេឃភ្លឺក្នុងថ្ងៃរ៉យ៉ាហាជ្ជីដែលជាថ្ងៃទីដប់នៃខែហ្ស៊ុលហិជ្ជះ អ្នកធ្វើហាជ្ជីត្រូវតម្រង់ទៅកាន់មីណាមុនពេលថ្ងៃរះ និងត្រូវដើរឱ្យលឿនត្រង់ចំណុចវ៉ាទីមូហាសសើរ។

ពេលទៅដល់មីណា គេត្រូវគប់គោលអាក៏ហ្ពះដែលជាគោលចុងក្រោយគេរាប់ពីទិសខាងក្រុងម៉ាក្កះចំនួនប្រាំពីរគ្រាប់ក្រួសជាបន្តបន្ទាប់។ ដោយគ្រាប់ក្រួសនោះមានទំហំប្រហែលប៉ុនគ្រាប់ល្ងើ។ ហើយត្រូវសូត្រតឹកពៀរ(الله أكبر)រាល់ពេលគប់គ្រាប់ក្រួសនីមួយៗ។

ក្រោយពីគប់គោលរួច គេត្រូវសំឡេះសត្វជំនូនរបស់គេ ប្រសិនបើអាចធ្វើបាន។

ក្រោយមក ត្រូវកោរ ឬកាត់សក់របស់គេសម្រាប់បុ្ុរស ដោយការកោរគឺប្រសើរជាង។ ចំណែកឯស្ត្រីវិញគឺត្រូវកាត់សក់របស់នាងប្រវែងមួយថ្នាំងដៃ ដោយមិនតម្រូវឱ្យកោរឡើយ។

នៅពេលដែលបានគប់គោល និងកោរសក់រួច គឺគេបានបញ្ចប់តំណមអៀហរ៉មដំបូងហើយ ហើយអ្វីគ្រប់យ៉ាងគឺត្រូវបានអនុញ្ញាតសម្រាប់គេវិញ លើកលែងតែការរួមមេត្រីប៉ុណ្ណោះ។

បន្ទាប់មក ត្រូវធ្វើដំណើរទៅកាន់ម៉ាក្កះដើម្បីតវ៉ាហ្វអ៊ីហ្វាហ្ពោះ

រួចសាអ៊ីហាជ្ជី ប្រសិនបើគេធ្វើហាជ្ជីតាម៉ាត់តួក ឬក៏ហាជ្ជីអ៊ីហ្វារ៉ទ ឬហាជ្ជីគីរ៉ន ដែលគេមិនទាន់បានសាអ៊ីក្រោយពីតវ៉ាហ្វគូទូម។ គេអាចពន្យារការតវ៉ាហ្វ និងសាអ៊ីរហូតដល់ពេលយប់ ឬនៅថ្ងៃបន្ទាប់ក៏បាន ទៅតាមពេលដែលមានភាពងាយស្រួលសម្រាប់គេ។

## ទីបួនៈ ទង្វើនៅបណ្ដាថ្ងៃតាស្ហរិក

នៅពេលដែលបានគេគប់គោល កោរសក់ តវ៉ាហ្វ និងសាអ៊ីរួច គឺគេបានបញ្ចប់គំណមអៀហរ៉មទាំងស្រុង ហើយអ្វីគ្រប់យ៉ាងគឺត្រូវបានអនុញ្ញាតសម្រាប់គេវិញ រួមទាំងការរួមមេត្រីផងដែរ។

ក្រោយពីរួចរាល់ គេត្រូវវិលត្រឡប់ទៅកាន់មីណាវិញដើម្បីស្នាក់នៅទីនោះនាយប់ទី១១ យប់ទី១២ និងយប់ទី១៣មួយយប់ទៀតចំពោះអ្នកដែលគ្មានការប្រញាប់។

គេត្រូវគប់គោលទាំងបីនៅពេលថ្ងៃជ្រេ។

នៅថ្ងៃទី១១ គេត្រូវគប់គោលទីមួយ ដែលជាគោលដែលស្ថិតនៅក្បែរម៉ាស្ជិត អាល់ខៃហ្វ ចំនួនប្រាំពីរគ្រាប់ក្រួសបន្តបន្ទាប់គ្នា។ ត្រូវសូត្រតឹកពៀរ(الله أكبر )រាល់ពេលគប់គ្រាប់ក្រួសនីមួយៗ។ ក្រោយមក គេត្រូវឈានទៅមុខបន្តិច រួចឈរសុំទូអាឲ្យបានយូរនូវអ្វីដែលគេប្រាថ្នា

ប្រសិនបើមិនងាយស្រួលទេនោះ
គឺអាចទូអាបន្តិចក៏បានដើម្បីកុំឱ្យបាត់បង់ការអនុវត្តតាមស៊ុណ្ណះ។

បន្ទាប់មក គេត្រូវគប់គោលកណ្ដាល ចំនួនប្រាំពីរគ្រាប់ក្រួសដូចគ្នា ក្រោយមក គេត្រូវឈរខាងឆ្វេងហើយតម្រង់មុខទៅកាន់គិបឡាត់ហើយសុំទូអាបួងសួង
ដូចក្រោយពេលដែលគប់គោលទីមួយដែរ។

បន្ទាប់មកទៀត គេត្រូវគប់គោលអាក៏ហ្ពះ ដោយត្រូវធ្វើដូចគ្នា
លើកលែងតែគេត្រូវចាកចេញភ្លាមដោយគ្មានការសុំទូអាបន្ទាប់ពីគប់គោលរួចនោះឡើយ។

ហើយនៅថ្ងៃទី១២ គេត្រូវគប់គោលដូចថ្ងៃទី១១ដែរ បន្ទាប់ពីថ្ងៃជ្រេ
ប្រសិនបើគេមានការប្រញាប់ចង់ចាកចេញ
គេអាចចាកចេញពីមីណាបានបន្ទាប់ពីគប់គោលហើយនោះ។

ប្រសិនបើគេគ្មានការប្រញាប់ទេ
គេអាចស្នាក់នៅមីណានាយប់ទី១៣មួយយប់ទៀត
ហើយត្រូវគប់គោលទាំងបីនាថ្ងៃទី១៣បន្ទាប់ពីថ្ងៃជ្រេ
ដូចដែលគេបានធ្វើកន្លងមក។
ហើយការពន្យារពេលស្នាក់នៅនាយប់ទី១៣មួយយប់ទៀត គឺល្អប្រសើរជាង។

ហើយប្រសិនបើគេពន្យារពេលនាថ្ងៃទី១២នៅឯមីណារហូតដល់ថ្ងៃលិចហើយនោះ

គឺវ៉ាជិប(ចាំបាច់)លើគេត្រូវស្នាក់នៅមីណានាយប់ទី១
៣មួយយប់ទៀត
ហើយត្រូវគប់គោលទាំងបីនាថ្ងៃទី១៣បន្ទាប់ពីថ្ងៃជ្រ
។

ប៉ុន្តែប្រសិនបើថ្ងៃបានលិចនាថ្ងៃទី១២ ខណៈរូបគេមិនទាន់បានចេញផុតពីមីណា ដោយមិនមែនជាការជ្រើសរបស់គេទេនោះ ដូចជាគេបានចេញដំណើរហើយ តែដោយសារមានការកកស្ទះឡានជាដើម និងផ្សេងទៀតនោះ គឺគេមិនតម្រូវឱ្យបន្តនៅដល់ថ្ងៃទី៣ឡើយ ព្រោះវាមិនមែនដោយសារតែការជ្រើសរើសរបស់គេទេ។

## ទីប្រាំមួយ៖ តវ៉ាហ្វវ៉ាហ្ទាក(តវ៉ាហ្វលា)

នៅពេលដែលអ្នកធ្វើហាជ្ជីមានបំណងចាកចេញពីក្រុងម៉ាក្កះទៅកាន់ស្រុកទេសរបស់ខ្លួនវិញ គឺគេមិនអាចចាកចេញបានទេ លុះត្រាតែគេបានតវ៉ាហ្វលាជាមុនសិន។

លើកលែងចំពោះស្ត្រីដែលមានរដូវ និងស្ត្រីក្រោយពេលសម្រាលកូនប៉ុណ្ណោះ គឺមិនត្រូវតវ៉ាហ្វវ៉ាហ្ទាកឡើយ។ ហើយក៏មិនចាំបាច់ឈរនៅមាត់ទ្វារម៉ាស្ជិតហារ៉មដើម្បីលានោះដែរ ព្រោះគ្មានការរាយការណ៍បែបនោះពីព្យាការីឡើយ។

ហើយត្រូវធ្វើការតវ៉ាហ្វវ៉ាហ្ទាកជាកិច្ចការចុងក្រោយរបស់គេដែលត្រូវបញ្ចប់នៅឯកាក់ហ្ពះ នៅពេលដែលគេមានបំណងចាកចេញពីក្រុងម៉ាក្កះ។

ប្រសិនបើគេបន្តនៅក្រោយពេលតវ៉ាហ្វវ៉ាហ្ទាករួច ដើម្បីរង់ចាំគ្នីគ្នា ឬរៀបចំកាបូប ឬទិញអ្វីមួយដែលចាំបាច់នៅតាមផ្លូវរបស់គេ នោះគ្មានបញ្ហាអ្វីនោះទេ ហើយក៏មិនតម្រូវឱ្យតវ៉ាហ្វវ៉ាហ្ទាកម្តងទៀតនោះដែរ លុះត្រាតែគេមានបំណងពន្យារពេលនៅក្នុងការធ្វើដំណើររបស់គេ ដូចជាគេចង់ធ្វើដំណើរនៅពេលព្រឹក ហើយក៏បានតវ៉ាហ្វវ៉ាហ្ទាក រួចក៏ពន្យារពេលធ្វើដំណើររហូតដល់ល្ងាចវិញ នោះគេត្រូវទៅតវ៉ាហ្វវ៉ាហ្ទាកម្តងទៀត ដើម្បីឱ្យកិច្ចការចុងក្រោយរបស់គេដែលត្រូវបញ្ចប់នៅឯកាក់ហ្ពះ។

***

# Index


សេចក្តីសង្ខេបអំពីរបៀបនៃការធ្វើហាជ្ជី 2
សេចក្តីផ្តើម 2
ទីមួយៈ  លក្ខខណ្ឌនៃការទទួលយកកិច្ចគោរពសក្ការៈ(អ៊ីហ្លាទាត់) 2
ទីមួយៈ ក្បួនច្បាប់នៃមីកត 5
ទីពីរៈ ប្រភេទនៃការធ្វើហាជ្ជី និងក្បួនច្បាប់របស់វា 6
ទីបីៈ របៀបធ្វើហាជ្ជី និងក្បួនច្បាប់របស់វា 8
ទីបួនៈ បម្រាមទាំងឡាយនៃអៀហរ៉ម 12
ទីប្រាំៈ របៀបតវ៉ាហ្វ(ការដើរប្រទក្សិណជុំវិញកាក់ហ្ពះ) 14
ទីប្រាំមួយៈ របៀបសាអ៊ី 18
របៀបនៃការធ្វើហាជ្ជី 22
ទីមួយៈ អៀហរ៉មហាជ្ជី 22
ទីពីរៈ ការស្នាក់នៅមីណា 24
ទីបីៈ ការស្នាក់នៅអារ៉ហ្វះនិងមុហ្សទើលីហ្វះ 25
ទីបួនៈ ទង្វើនៅថ្ងៃរ៉យ៉ាហាជ្ជី 28
ទីបួនៈ ទង្វើនៅបណ្តាថ្ងៃតាស្ហរិក 30
ទីប្រាំមួយៈ តវ៉ាហ្វវ៉ាហ្ទាក(តវ៉ាហ្វលា) 33